# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១

នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- យោងតាមសំណើរបស់អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវ** (STEUNG HAV SEZ) ដែលមានទីតាំងស្ថិតនៅឃុំអូរត្រេះ និងឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវ** មានទំហំ មួយលាន ប្រាំបួនរយម្ភៃបួនពាន់ ប្រាំរយហុកសិបប្រាំបី ម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវ** ដូចមានកំណត់ក្នុង មាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសស្ទឹងហាវនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងក្រុមហ៊ុន អ៊ែកវូត អ៊ិនវេសមេន គ្រុប ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែ កុម្ភៈ ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា សោភា**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ប្លង់ទីតាំងដីគម្រោងអភិវឌ្ឍន៍កំពង់ផែអន្តរជាតិស្ទឹងហាវ និងតំបន់សេដ្ឋកិច្ចពិសេស

## របស់ក្រុមហ៊ុន ATTWOOD INVESTMENT GROUP CO., LTD

### ស្ថិតនៅភូមិ២ ឃុំអូរត្រេះ និងឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ




តារាងនិយាមកានៃចំណុចគោល

( ប្រភព: អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ )

Projection UTM.Zone 48N, WGS84.

| Points_ID | Easting | Northing | Points_ID | Easting | Northing |
|---|---|---|---|---|---|
| A | 348261.7911 | 1186376.238 | C | 346782.3438 | 1187057.889 |
| B | 348294.9388 | 1186835.448 | D | 345948.0555 | 1187261.781 |

តារាងនិយាមកានៃចំណុចព្រំដី

Projection UTM.Zone 48N, WGS84.

| Points_ID | Easting | Northing | Points_ID | Easting | Northing |
|---|---|---|---|---|---|
| 1 | 348642.042 | 1185502.509 | 32 | 347574.356 | 1186935.151 |
| 2 | 348584.310 | 1185573.400 | 33 | 347513.907 | 1186443.601 |
| 3 | 348649.290 | 1185627.510 | 34 | 346926.690 | 1186547.407 |
| 4 | 348353.490 | 1185905.460 | 35 | 347067.768 | 1186785.789 |
| 5 | 348487.788 | 1186028.877 | 36 | 346826.307 | 1186787.487 |
| 6 | 348551.684 | 1185956.200 | 37 | 346777.044 | 1186557.709 |
| 7 | 348594.469 | 1186002.967 | 38 | 346870.553 | 1186551.271 |
| 8 | 348676.193 | 1185938.484 | 39 | 346879.664 | 1186334.315 |
| 9 | 348885.277 | 1186213.400 | 40 | 347131.475 | 1186094.919 |
| 10 | 348872.000 | 1186258.000 | 41 | 347632.104 | 1185971.834 |
| 11 | 348990.570 | 1186236.124 | 42 | 348071.189 | 1185676.278 |
| 12 | 349093.803 | 1186240.250 | 43 | 348407.885 | 1185519.535 |
| 13 | 349304.159 | 1186205.009 | 44 | 348536.346 | 1185445.542 |
| 14 | 349326.911 | 1186246.937 | 45 | 348226.084 | 1186168.829 |
| 15 | 348851.000 | 1186784.000 | 46 | 348238.835 | 1186247.853 |
| 16 | 348729.888 | 1186816.429 | 47 | 348053.103 | 1186187.629 |
| 17 | 348691.469 | 1186884.237 | 48 | 348065.841 | 1186266.540 |
| 18 | 348650.400 | 1186868.938 | 49 | 348471.739 | 1185417.949 |
| 19 | 348632.852 | 1186829.822 | 50 | 348262.802 | 1185519.461 |
| 20 | 348584.698 | 1186688.857 | 51 | 348192.777 | 1185324.681 |
| 21 | 348445.000 | 1186811.000 | 52 | 347935.580 | 1185702.529 |
| 22 | 348325.116 | 1186769.672 | 53 | 347873.708 | 1185578.696 |
| 23 | 348295.725 | 1187087.461 | 54 | 347622.550 | 1185771.182 |
| 24 | 347960.397 | 1187049.040 | 55 | 347699.144 | 1185879.833 |
| 25 | 348282.717 | 1187228.108 | 56 | 345798.647 | 1186482.695 |
| 26 | 347970.258 | 1187219.261 | 57 | 345549.955 | 1186469.428 |
| 27 | 347942.570 | 1186835.163 | 58 | 345501.587 | 1186786.286 |
| 28 | 347895.649 | 1186837.881 | 59 | 345548.672 | 1187001.365 |
| 29 | 347874.738 | 1186563.429 | 60 | 345779.623 | 1187001.388 |
| 30 | 347705.875 | 1186582.423 | 61 | 345714.450 | 1186777.057 |
| 31 | 347732.888 | 1186849.914 | 62 | 345782.826 | 1186774.394 |

## សញ្ញាសំគាល់

▲ ចំណុចប្រធពីភាគ

● ចំណុចព្រំដី

——— ព្រំដី

▨ ក្បាលដីស្នើសុំវាស់វែង

ក = ១៧២៦២១៧ ម៉ែត្រក្រឡា

ខ = ២៧៧៤៨ ម៉ែត្រក្រឡា

គ = ៣៩៣៨៣ ម៉ែត្រក្រឡា

ឃ = ១៣១២២០ ម៉ែត្រក្រឡា

ង = ៤២១៧១ ម៉ែត្រក្រឡា (ដីពុំទាន់មានប័ណ្ណសំគាល់សិទ្ធិ)

ក្រឡាផ្ទៃសរុប : ១៩៦៦៧៣៩ ម៉ែត្រក្រឡា

- នេះចំណុចនិយាមកាពហុកោណជុំវិញដីប៉ុណ្ណោះ ត្រូវគោរពដីសាធារណៈ ( អូរ.ចំណីអូរ) ដូចប្លង់ក្បាលដីមិនទាន់បង្រួម ។

ឧបករណ៍វាស់វែង : Totalstation Topcon GPT-3005W

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យត្រឹមត្រូវ | វាស់វែង និងគូរដោយ |
|---|---|---|
| ខេត្តព្រះសីហនុ ថ្ងៃទី១៥ខែ ៥ ឆ្នាំ ២០១១ | ស្ទឹងហាវ ថ្ងៃទី ១៥ ខែ ៥ ឆ្នាំ ២០១១ | ខេត្តព្រះសីហនុ ថ្ងៃទី ១៣ ខែ ៥ ឆ្នាំ ២០១១ |
| មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តព្រះសីហនុ | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ស្រុកស្ទឹងហាវ | |
| ស៊ូ សុខ | សំរិទ្ធ ក្ញុសលេ | ស៊ុន សឿន ម៉ៅ ដា |